![KIDS GOD WORSHIP]

www.kidworship.kr



42Page



43Page



44Page

# សូដុមនិងកូម៉ូរ៉ា

- 7th Story -

**Nar** ប្រជាជននៅក្រុងសូដុមនិងក្រុងកូម៉ូរ៉ាចាស់ បានធ្វើបាបទាស់ប្រឆាំងនឹងព្រះជាម្ចាស់។ អំពើបាបរបស់ពួកគេ ធំណាស់។ ដូច្នេះហើយ ព្រះជាម្ចាស់បានសំរេចចិត្ត នឹងប្រើភ្លើងដុតកំទេចក្រុងសូដុមនិងក្រុងកូម៉ូរ៉ា។ ប៉ុន្តែព្រះជាម្ចាស់បានប្រាប់អ័ប្រាហាំអំពីផែនការរបស់ទ្រង់ថា

**God** យើងនឹងបំផ្លាញក្រុងសូដុមនិងក្រុងកូម៉ូរ៉ាចោល។

**Nar** ពេលអ័ប្រាហាំបានឮ អំពីផែនការរបស់ព្រះជាម្ចាស់ហើយ គាត់មានការព្រួយបារម្ភចំពោះក្មួយប្រុសរបស់គាត់ឈ្មោះឡុត ដែលបានរស់នៅក្រុងសូដុមជាខ្លាំង។ ដូច្នេះ អ័ប្រាហាំបានសុំដល់ព្រះជាម្ចាស់យ៉ាងខ្លាំងថា

**Abraham** ព្រះជាម្ចាស់អើយ! បើមានមនុស្សសុចរិតត្រឹមតែ10នាក់នៅក្រុងសូដុមនិងក្រុងកូម៉ូរ៉ា តើទ្រង់នឹងអត់ទោសអោយពួកគេបានទេ?

**God** បើមានមនុស្សសុចរិត10នាក់នៅក្រុងសូដុមនិងក្រុងកូម៉ូរ៉ា នោះយើងនឹងអត់ទោសអោយហើយក៏មិនបំផ្លាញពួកគេចោលដែរ។

---

**Nar** ប៉ុន្តែ នៅក្រុងសូដុម គ្មានមនុស្សសុចរិត សូម្បីតែ១០នាក់ឡើយ។ ទោះបីព្រះជាម្ចាស់បានសម្រេចចិត្តបំផ្លាញក្រុងសូដុមមែន ប៉ុន្តែ ព្រះជាម្ចាស់ក៏បានមានគម្រោងជួយសង្គ្រោះឡុតនិងក្រុមគ្រួសាររបស់គាត់ដែរ។ ថ្ងៃមួយ ជិតដល់ម៉ោងអាហារពេលល្ងាចហើយ នោះទេវតារបស់ព្រះជាម្ចាស់បានមកដល់ផ្ទះឡុត។ គាត់បានដឹងថា ពួកគេគឺជាទេវតារបស់ព្រះជាម្ចាស់។ ពេលនោះ ឡុតក៏បានអញ្ជើញទេវតាទាំងពីរនាក់ឲ្យចូលក្នុងផ្ទះរបស់គាត់ ហើយបានរៀបអាហារពេលល្ងាចឲ្យពួកគេញ៉ាំដែរ។ បន្ទាប់ពីពួកគេបានញ៉ាំអាហាររួចហើយ ពេលនោះ មានប្រុសៗជាច្រើន ដែលមកពីគ្រប់ទីកន្លែងក្នុងក្រុងសូដុម បានមកឡោមព័ទ្ធផ្ទះគាត់ ហើយបានទាមទារឱ្យគាត់នាំបុរសទាំងពីរនាក់នោះមកជួបពួកគេ។

---

**Lot** ទេៗសំលាញ់! បុរសទាំងនោះ ជាភ្ញៀវពិសេសរបស់ខ្ញុំទេ។

**Nar** ទោះបីឡុតបានព្យាយាមបញ្ឈប់ពួកប្រុសៗទាំងនោះក៏ដោយ ប៉ុន្តែគាត់នៅតែមិនអាចហាមឃាត់ពួកគេទាំងនោះបានឡើយ។

**Nar** ពេលនោះ ទេវតាទាំងពីរ បានទាញឡុតឲ្យចូលទៅក្នុងផ្ទះហើយ បិទទ្វារជិត។ បន្ទាប់មក ទេវតាទាំងពីរ ក៏បានធ្វើឲ្យភ្នែកពួកទាំងនោះទៅជាខ្វាក់។ ដូច្នេះ ពួកគេមិនអាចរកឃើញទ្វារផ្ទះបានទេ។ បន្ទាប់មក ទេវតាទាំងពីរនិយាយទៅកាន់ឡុតថា

**Angel** ដោយសារតែមនុស្សក្នុងទីក្រុងនេះ បានធ្វើបាបទាស់ប្រឆាំងនិងព្រះអម្ចាស់យ៉ាងខ្លាំង ដូច្នេះហើយ ព្រះជាម្ចាស់បានចាត់ពួកយើងអោយមកបំផ្លាញទីក្រុងនេះចោល។

**Lot** អូ......!.ពិត...មែន?

**Angel** លឿនឡើងៗ! ចូរឯងនាំប្រពន្ធនិងកូនស្រីទាំងពីររបស់ឯងចាកចេញពីក្រុងនេះទៅ។

---


45Page

**Nar** ព្រះជាម្ចាស់មានបំណងចង់បំផ្លាញក្រុងសូដុមនិងប្រជាជនក្រុងនោះ ចោលទាំងអស់។ ប៉ុន្តែដោយសារអេប្រាហាំបានទូលសុំដល់ព្រះជាម្ចាស់ ទើបទ្រង់បានជួយសង្គ្រោះឡុតនិងក្រុមគ្រួសាររបស់គាត់។ បន្ទាប់មក ទេវតាក៏បានហាមដល់ឡុតថា

**Angel** កុំងាកមើលក្រោយឲ្យសោះ ហើយក៏កុំឈប់នៅទីវាលរាបដែរ។ ចូរឯងរត់ទៅលើភ្នំទៅ!

**Lot** លោកម្ចាស់អើយ! សូមអោយខ្ញុំរត់ទៅទីក្រុងសូអារដែលនៅជិតនេះវិញ។

**Nar** ឡុតបានសុំទៅកាន់ទេវតាទាំងពីរ។

---


46Page

**Nar** ពេលឡុតបានទៅដល់ក្រុងសូអា ព្រះអាទិត្យបានរះបំភ្លឺផែនដីហើយ។ ពេលនោះ ព្រះជាម្ចាស់ក៏បានទំលាក់ភ្លើងដុតលើក្រុងសូដុមនិងកូម៉ូរ៉ា ដែលមានមនុស្ស សត្វ និងបន្លែទាំងអស់នៅលើដីត្រូវបានឆេះអស់ទៅ។ ប្រពន្ធរបស់ឡុតបានក្លាយជារូបចំលាក់អំបិល ដោយសារតែនាងបានងាកមើលក្រោយ។


47Page


48Page


49Page